**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

# សុន្ទរកថា
# ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
# ថ្លែងក្នុងឱកាសពិធីអបអរសាទរខួបឆ្នាំទី ១៩ ទិវាប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ
# នៃព្រះរាជាណាចក្រកម្ពុជា(២៤/០៩/១៩៩៣-២៤/០៩/២០១២)

-សូមថ្វាយបង្គំសម្តេច អ្នកអង្គម្ចាស់ និង សូមគោរពលោកជំទាវ ឯកឧត្តម លោកស្រី អស់លោក នាងកញ្ញា ជាទីគោរពរាប់អានដ៏ខ្ពង់ខ្ពស់

ថ្ងៃនេះ ទូលបង្គំ-ខ្ញុំមានកិត្តិយស និង សោមនស្សរីករាយចំពោះព្រះវត្តមាន និង វត្តមានរបស់សម្តេច អ្នកអង្គម្ចាស់ លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញាដែលបានលះបង់ពេលវេលាអញ្ជើញចូលរួមក្នុងកម្មវិធីបុណ្យអបអរសាទរខួបឆ្នាំទី ១៩ ទិវាប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (២៤/០៩/១៩៩៣-២៤/០៩/២០១២) ដែលប្រារព្ធធ្វើនៅសាលប្រជុំនៃសណ្ឋាគារ Cambodiana នាពេលនេះ ក្នុងក្របខ័ណ្ឌកិច្ចសហការ និង ការជួយឧបត្ថម្ភរបស់អង្គការមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ (Konrad Adenauer Stiftung) ។ ព្រះកាយវិការ និង កាយវិការនេះ ជាសក្ខីភាពនៃការយកចិត្តទុកដាក់ និង សមានចិត្ត ដើម្បីរំលឹកឡើងវិញនូវមេរៀន និង បទពិសោធន៍ទាំងឡាយ ជុំវិញការធ្វើច្បាប់កំពូលរបស់ជាតិគឺរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និង ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាបន្តបន្ទាប់ ។

**អង្គពិធីទាំងមូលជាទីគោរពដ៏ខ្ពង់ខ្ពស់**

ទូលបង្គំ-ខ្ញុំ សូមព្រះអនុញ្ញាត និង អនុញ្ញាតរំលឹកឡើងវិញដោយសង្ខេបនូវព្រឹត្តិការណ៍សំខាន់ៗខ្លះៗ ដែលពាក់ព័ន្ធនឹងការបង្កើតរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣របស់ព្រះរាជាណាចក្រកម្ពុជានៃយើង ។

១-ក្រោមរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាឆ្នាំ១៩៤៧ ក្នុងសម័យសង្គមរាស្ត្រនិយម ពីឆ្នាំ១៩៥៥ ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧០ ព្រះរាជាណាចក្រកម្ពុជា ជាកោះសន្តិភាពមួយ (Une oasis de paix) មានសុខសន្តិភាព ស្ថិរភាព និង វឌ្ឍនភាពថ្កុំថ្កើងរុងរឿង ផលិតផលក្នុងស្រុកសរុបឆ្នាំ១៩៦៩ សម្រាប់ពលរដ្ឋម្នាក់ប្រមាណ ៥.០០០ រៀល ក្នុងមួយឆ្នាំប្រៀបជាមាសប្រមាណ ១ដំឡឹង ៦ជី ។

២-ចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ កម្ពុជាបានធ្លាក់ខ្លួនដ៏សែនវេទនាក្នុងភ្លើងសង្គ្រាមអស់ជាងពីរទសវត្ស

ឆ្លងកាត់ទុក្ខសោកវិនាសកម្មគ្រប់យ៉ាង មហាសោកស្តាយក្រោមការផ្លាស់ប្តូររបបនយោបាយ និង ផ្លាស់ប្តូររដ្ឋធម្មនុញ្ញចំនួន ៤លើក ។

៣-ថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៨៧ ការជួបចរចាស្វែងរកសន្តិភាព លើកដំបូងរវាងសម្តេចព្រះ **នរោត្តម សីហនុ** និង ឯកឧត្តម **ហ៊ុន សែន** នៅប្រទេសបារាំង បានបើកផ្លូវឱ្យមានការចរចាជាបន្តបន្ទាប់ជិត ៤ឆ្នាំ រហូតដល់គោលដៅរួមមួយគឺ កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា (ហៅកាត់ថា កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស) ចុះហត្ថលេខាពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ច្បាប់ដើមនៃកិច្ចព្រមព្រៀងនេះដែល អត្ថបទធ្វើជាភាសាចិន អង់គ្លេស បារាំង ខ្មែរ និង រុស្សី មានតម្លៃស្មើគ្នានឹងត្រូវតម្កល់រក្សាទុកជាមួយរដ្ឋាភិបាលសាធារណរដ្ឋបារាំង និង រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី ដែលនឹងផ្ញើនូវច្បាប់ចម្លងត្រឹមត្រូវជូនទៅបណ្តារដ្ឋហត្ថលេខី និង ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។








៤-ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ សម្តេចព្រះ **នរោត្តម  សីហនុ** ក្នុងព្រះឋានៈជាប្រធានឧត្តមក្រុម-ប្រឹក្សាជាតិ（SNC）បានយាងមាតុភូមិនិវត្តពីទីក្រុងប៉េកាំង ដោយមានឯកឧត្តម **ហ៊ុន  សែន** តំណាងឱ្យរដ្ឋកម្ពុជា ដង្ហែអមក្នុងព្រះទីនាំងអាកាសយានពិសេស ក៏ដូចជាក្នុងព្រះទីនាំងរថយន្តពិសេសជាមួយព្រះអង្គរហូតដល់ព្រះបរមរាជវាំងចតុមុខប្រកបដោយសុខសុវត្ថិភាពបំផុត ។






៥-ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩១ រដ្ឋាភិបាលនៃរដ្ឋកម្ពុជា និង គណបក្សប្រជាជនកម្ពុជាផ្សព្វផ្សាយសេចក្តីថ្លែងការណ៍មួយ ថ្កោលទោសរដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និង ទទួលស្គាល់សម្តេចព្រះ **នរោត្តម សីហនុ** ជាប្រមុខរដ្ឋ។ គ្រប់ក្រសួង មន្ទីរ ខេត្ត ក្រុង បានប្រារព្វធ្វើមិទ្ទិញ និង ធ្វើញត្តិគាំទ្រសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩១។ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩១ គណបក្សប្រជាជនកម្ពុជា និង ហ៊្វុនស៊ីនប៉ិច បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយមាន ០៦ប្រការ ក្នុងគោលបំណងបង្កើតការជឿទុកចិត្តគ្នា ថែរក្សាស្ថិរភាពខាងនយោបាយ និង បង្កលក្ខណៈសម្បត្តិថ្វាយចំពោះសម្តេចព្រះ **នរោត្តម សីហនុ** បំពេញព្រះរាជបេសកកម្មជូនជាតិបានល្អ។




៦-ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ ការបោះឆ្នោតសាកលជ្រើសតាំងសមាជិក សភាធម្មនុញ្ញត្រូវបានចាត់ចែងរៀបចំដោយ អ៊ុន តាក់ (UNTAC)។ ប្រជាពលរដ្ឋខ្មែរជានីតិជន ចំនួន ៨៦.៥៩ % បានទៅបោះឆ្នោត ទោះបីមានការគម្រាមកំហែង និង ធ្វើពហិការពីខ្មែរក្រហមក្តី។ គណបក្សនយោបាយចំនួន ៤ បានទទួលអាសនៈនៅសភាធម្មនុញ្ញ ក្នុងចំណោមគណបក្សនយោបាយទាំង ២០ នៅកម្ពុជា ដែលបានឈរឈ្មោះជាបេក្ខជន គឺគណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ៥៨ អាសនៈ គណបក្សប្រជាជនកម្ពុជាទទួលបាន ៥១ អាសនៈ គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាទទួលបាន ១០ អាសនៈ និង គណបក្សម៉ូលីណាការទទួលបាន ០១ អាសនៈ។ សភាធម្មនុញ្ញ មានសមាជិកចំនួន ១២០ រូប។

៧-វិបត្តិមួយបានកើតឡើងក្រោយពីមានលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមខេត្ត-ក្រុង។ គណបក្សប្រជាជនកម្ពុជា បដិសេធលទ្ធផលនៃការបោះឆ្នោត ដោយមូលហេតុភាពមិនប្រក្រតីជាច្រើន បង្កដោយ

អ៊ុន តាក់ ហើយអាចនឹងឈានទៅដល់ការធ្វើអប្បគមន៍ ០៦ ខេត្ត នៅបូព៌ា ។ វិបត្តិនេះត្រូវបានដោះស្រាយចេញរួចតាមការព្រមព្រៀងគ្នា បង្កើតរដ្ឋាភិបាលជាតិបណ្តោះអាសន្នមួយ ។



៨-ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចព្រះ **នរោត្តម សីហនុ** ជាព្រះប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា និង ការចូលរួមពីសំណាក់ឯកឧត្តម **យ៉ាស៊ូស៊ី អាកាស៊ី** ប្រមុខនៃអ៊ុនតាក់ ជាតំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិប្រចាំកម្ពុជា សភាធម្មនុញ្ញបានប្រារព្ធបើកសម័យប្រជុំលើកដំបូងរបស់ខ្លួនហើយនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ១៩៩៣ នេះ សភាធម្មនុញ្ញក៏បានអនុម័តជាឯកច្ឆន្ទ័លើសេចក្តីសម្រេចចិត្តមួយ ប្រកាសថារដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ជាអំពើខុសច្បាប់ ហើយបង្កើតឡើងវិញនូវនិរន្តរភាពនៃភាពស្របច្បាប់របស់កម្ពុជា ដោយបានថ្វាយដល់សម្តេចព្រះ **នរោត្តម សីហនុ** នូវព្រះរាជបុព្វសិទ្ធិជាព្រះប្រមុខរដ្ឋនៃកម្ពុជាឡើងវិញ ទោះបីមានប្រតិកម្មមិនល្អពីអ្នកការទូតខ្លះក៏ដោយ ។ ថ្ងៃទី១៥ ខែមិថុនា ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិផ្តល់សច្ចានុម័តលទ្ធផលបោះឆ្នោត និង ទទូចសុំឱ្យសម្តេចព្រះ **នរោត្តម សីហនុ** បំពេញព្រះរាជតួនាទី ។



៩-ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៣ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះប្រមុខរដ្ឋទ្រង់តែងតាំងសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** និង សម្តេច **ហ៊ុន សែន** ជាសហនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា ដោយប្រគល់ភារកិច្ចឱ្យសហនាយករដ្ឋមន្ត្រីរៀបចំផ្គូផ្គងឥស្សរជនរបស់គណបក្សទាំង ៤ មានអាសនៈក្នុងសភាធម្មនុញ្ញឱ្យធ្វើជាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី ដឹកនាំក្រសួងស្ថាប័ន នៃរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា។ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩៣ គណបក្សប្រជាជនកម្ពុជាទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។

១០-ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៣ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** និង សម្តេច **ហ៊ុន សែន** បានព្រមព្រៀងគ្នាលើសមាសភាពរដ្ឋាភិបាលជាតិបណ្តោះអាសន្ន។ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៣ រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា ប្រជុំលើកទី១ ក្រោមអធិបតីភាពសហនាយករដ្ឋមន្ត្រី ។

១១-ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣ សម័យប្រជុំពេញអង្គលើកទី ១ នៃសភាធម្មនុញ្ញ ដើម្បីអនុម័តបទបញ្ជាផ្ទៃក្នុងសភាធម្មនុញ្ញ និង បានធ្វើការបោះឆ្នោតជ្រើសតាំងសម្តេច **សឺន សាន** ជាប្រធាន សម្តេច **ជា ស៊ីម** ជាអនុប្រធានទី១ និង ឯកឧត្តម **អ៊ឹង គៀត** ជាអនុប្រធានទី២ នៃសភាធម្មនុញ្ញ។ ក្នុងសម័យប្រជុំពេញអង្គសភាធម្មនុញ្ញក៏បានអនុម័តបង្កើតគណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ ដែលមានសមាសភាព ២៦ រូប ដឹកនាំដោយសម្តេច **សឺន សាន** ជាប្រធាន ឯកឧត្តម **ចែម ស្ងួន** ជាអនុប្រធាន និង ឯកឧត្តម **តាវ សេងហួ** ជាអ្នករាយការណ៍ ។ ក្នុងសម័យប្រជុំពេញអង្គសភាធម្មនុញ្ញក៏បានបោះឆ្នោតទុកចិត្តរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជាដែលមានសមាជិករដ្ឋាភិបាល ៧១ រូប មាន ២៨ ក្រសួងដែលមានកម្មវិធីនយោបាយ រយៈពេលបីខែខាងមុខ ។ ទន្ទឹមគ្នានោះ សភាធម្មនុញ្ញបានអនុម័តទង់ជាតិ និង ភ្លេងជាតិផងដែរ។






១២-គណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញបានបំពេញកិច្ចការរបស់ខ្លួនចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៣ ហើយភាគច្រើនលើសលប់កិច្ចប្រជុំរបស់គណៈកម្មការអចិន្ត្រៃយ៍នេះស្ថិតក្រោមអធិបតីភាពរបស់ឯកឧត្តម **ចែម ស្ងួន** អនុប្រធានគណៈកម្មការ ។ ម្យ៉ាងទៀតគណៈកម្មការមានគោលការណ៍រក្សាការសម្ងាត់នៃដំណើរការប្រជុំ និង បានបញ្ចប់ការងារបឋមរបស់ខ្លួននៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៣ ក្នុងការរៀបរៀងសេចក្តីព្រាងរដ្ឋធម្មនុញ្ញ។



១៣-នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៣ គណៈប្រតិភូជាន់ខ្ពស់របស់សភាធម្មនុញ្ញ និង របស់រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជាបានយាង និង អញ្ជើញទៅទីក្រុងព្យុងយ៉ាងប្រទេសកូរ៉េខាងជើង ដើម្បីយក

សេចក្តីព្រាងរដ្ឋធម្មនុញ្ញនេះទៅក្រាបបង្គំទូលថ្វាយសម្តេចព្រះ **នរោត្តម សីហនុ** ព្រះប្រមុខរដ្ឋ ដើម្បីសូមទ្រង់មានព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់បំផុត ។



ការប្រជុំថ្នាក់ដឹកនាំកំពូលរបស់គណបក្សធំបីមានអាសនៈក្នុងសភាធម្មនុញ្ញ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចព្រះ **នរោត្តម សីហនុ** នៅឯក្រុងព្យុងយ៉ាងនោះ ហើយដែលនាំដល់ការព្រមព្រៀងគ្នាទៅលើសេចក្តីព្រាងចុងក្រោយនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និង រក្សាទុកជាការសម្ងាត់រហូតដល់ថ្ងៃបើកសម័យប្រជុំពេញអង្គខាងមុខ ។

១៤-សម័យប្រជុំពេញអង្គលើកទី២ នៃសភាធម្មនុញ្ញចាប់ផ្តើមពិនិត្យពិភាក្សាលើសេចក្តីព្រាងរដ្ឋធម្មនុញ្ញចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៩៣ ។ នៅថ្ងៃទី២១ ខែ ឆ្នាំដដែលវេលាម៉ោង ០៨:០០ ព្រឹក **សភាធម្មនុញ្ញបានធ្វើការបោះឆ្នោតអនុម័តលើអត្ថបទសេចក្តីព្រាងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទាំងមូលដោយមានចំនួន ១១៣ សំឡេងយល់ព្រម ០៥ សំឡេង មិនយល់ព្រម និង ០២ សំឡេងអនុបវាទ** ព្រមទាំងត្រូវបានដាក់ជូនសម្តេច **ជីន សាន** ប្រធានសភាធម្មនុញ្ញចុះហត្ថលេខានៅថ្ងៃខែឆ្នាំដដែល ។






១៥-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រូវបានព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រមដំបូងប្រកាសឱ្យប្រើជាផ្លូវការចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយក្នុងថ្ងៃដដែលនេះ សភាធម្មនុញ្ញបានក្លាយទៅជារដ្ឋសភានីតិកាលទី ១ ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយអនុលោមតាមវាក្យខ័ណ្ឌទី១ មាត្រា១៣៦ នៃរដ្ឋធម្មនុញ្ញ ។ ព្រះមហាក្សត្រ តែងតាំងសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ជានាយករដ្ឋមន្ត្រីទី១ សម្តេច **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីទី២ ។



រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានចែកចេញជា ១៤ ជំពូកនិង ១៣៩ មាត្រា ព្រមទាំងមានឧបសម្ព័ន្ធ ៦ ភ្ជាប់នឹងបញ្ជីរាយនាមគណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ។



១៦-ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៣ ការចុះហត្ថលេខាលើអនុសារណៈព្រមព្រៀងគ្នារវាងគណបក្ស ហ៊្វុន សិុនប៉ិច និង គណបក្សប្រជាជនកម្ពុជា មាន ០៤ ចំណុច សំដៅបន្តអនុវត្តឱ្យកាន់តែល្អនូវកិច្ចព្រមព្រៀង ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩១ និង បន្តពង្រឹង និង ពង្រីកកិច្ចសហការគ្នាក្នុងរដ្ឋសភា និង ក្នុងរាជរដ្ឋាភិបាល និង នៅគ្រប់លំដាប់ថ្នាក់។

១៧-ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ១៩៩៣ រដ្ឋសភាប្រជុំពេញអង្គបោះឆ្នោតជ្រើសតាំងសម្តេច **ជា ស៊ីម** ជាប្រធានរដ្ឋសភា និង ជ្រើសតាំងរចនាសម្ព័ន្ធដឹកនាំរដ្ឋសភា

១៨-ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ១៩៩៣ គណៈរដ្ឋមន្ត្រីប្រជុំលើកទី១ ក្រោមអធិបតីភាពនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២។

១៩-ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ១៩៩៣ រដ្ឋសភានីតិកាលទី ១ បោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល។







គណៈអធិបតី សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា សមាជិក សមាជិកានៃអង្គពិធីជាទីគោរពដ៏ខ្ពង់ខ្ពស់

ការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ គឺជាការបើកសករាជថ្មីរបស់ជាតិ និង ប្រជាជនកម្ពុជា ញ៉ាំងឱ្យយើងមានច្បាប់កំពូលមួយដ៏មានសារៈសំខាន់បំផុត សម្រាប់លើកស្ទួយកិត្យានុភាពសេចក្តីថ្លៃថ្នូររបស់ជាតិ ក្នុងឋានៈជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍មិនចូលបក្សសម្ព័ន្ធ។ ម្យ៉ាងវិញទៀតគឺជាឱកាសនាំឱ្យរដ្ឋសភានីតិកាលទី ១ រាជរដ្ឋាភិបាល អង្គការរដ្ឋទាំងអស់គ្រប់ជាន់ថ្នាក់ និង ប្រទេសជាតិមាននយោបាយ និង លទ្ធភាពជាបណ្តើរៗឆ្លើយតបយ៉ាងត្រឹមត្រូវចំពោះបេសកកម្មជាប្រវត្តិសាស្ត្រ ដើម្បីបង្រួបបង្រួមផ្សះផ្សាជាតិ ឯកភាពជាតិ សន្តិភាព ពេញលេញ ការស្តារ

និង អភិវឌ្ឍន៍ប្រទេសជាតិឡើងវិញលើគ្រប់វិស័យទទួលបាននូវសមានចិត្តស្រឡាញ់ រាប់អាន ការជួយឧបត្ថម្ភ គាំទ្រពីបណ្តាប្រទេសជាមិត្ត និង ពីសហគមន៍អន្តរជាតិ ។

ជាការពិតណាស់យើងនៅចងចាំថា ពេលនោះភាគីខ្មែរក្រហមមិនត្រឹមតែធ្វើពហិការមិនចូលរួមការបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែគេបានខិតខំពង្រឹងអង្គការចាត់តាំងនយោបាយ និង យោធាធ្វើជាកម្លាំងមួយប្រឆាំងរាជរដ្ឋាភិបាលស្របច្បាប់កើតចេញពីការបោះឆ្នោត ។ ពោលគឺសង្គ្រាមត្រូវបានបន្តរយៈពេលប្រមាណ៥ឆ្នាំទៀត គិតពីពេលដែលអ៊ុនតាក់ដកចេញពីកម្ពុជា ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៣ អ៊ុន តាក់ ដកចេញដោយបន្សល់ទុកឱ្យកម្ពុជានូវតំបន់ពីរ រដ្ឋបាលពីរ ប្រឈមមុខបដិបក្ខស្លាប់រស់ ។ អាស្រ័យដោយនយោបាយឈ្នះឈ្នះរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាចុង ឆ្នាំ១៩៩៨ ការបង្រួបបង្រួមជាតិ ឯកភាពជាតិ ឯកភាពទឹកដី សន្តិភាពពេញលេញ ទើបបានកើតមានពិតប្រាកដក្នុងព្រះរាជាណាចក្រកម្ពុជា ។







ក្នុងឱកាសនេះ ទូលបង្គំ ខ្ញុំសូមថ្លែងនូវកត្តញ្ញូតាធម៌ និង ការគោរពកោតសរសើរដ៏ស្មោះអស់ពីដួងចិត្ត ចំពោះថ្នាក់ដឹកនាំគណបក្សនយោបាយទាំងបួន ដែលមានអាសនៈក្នុងសភាធម្មនុញ្ញ ដែលបានព្រមព្រៀងសម្របសម្រួលគ្នា និង ចំពោះគណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញរបស់សភាធម្មនុញ្ញឆ្នាំ១៩៩៣ សមាជិកសមាជិកាសភាធម្មនុញ្ញទាំងមូល ដែលបានបូជាកម្លាំងកាយចិត្ត និង ប្រាជ្ញាតាក់តែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញ មានរយៈពេលប្រមាណបីខែធ្វើបានចប់ ហើយបានដាក់ជូនសភាធម្មនុញ្ញប្រជុំពិភាក្សា និង អនុម័តចប់សព្វគ្រប់ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។ ទូលបង្គំ ខ្ញុំគិតថា តាំងពីបុព្វកថា ជំពូកទី១ ដល់ជំពូកទី១៤ ឬ ពីមាត្រា ១ ដល់មាត្រា ១៣៩ រាប់ទាំងឧបសម្ព័ន្ធ គឺផ្អែកលើគោលការណ៍ទាំងអស់៦ចំណុច ដែលមានចែងក្នុងឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និង ផ្អែកលើឆន្ទៈរបស់ប្រជាពលរដ្ឋ៩0% តំណាងដោយសភាធម្មនុញ្ញ កើតពីការបោះឆ្នោតសាកលចាត់ចែងដោយ UNTAC ។ ម្យ៉ាងទៀតឆ្លងពីរដ្ឋសភានីតិកាលទី១ រហូតដល់រដ្ឋសភានីតិកាលទី៤ បច្ចុប្បន្នយើងឃើញថា មានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញចំនួន 0៦ លើក ព្រមទាំងមានធ្វើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិមាន 0៧ មាត្រា មួយទៀត ដែលទាំងអស់ខាងលើនេះ គឺសុទ្ធសឹងផ្អែកលើភាពចាំបាច់របស់ព្រះរាជាណាចក្រកម្ពុជា មានហេតុផលត្រឹមត្រូវ ផ្អែកលើពិធីសារចំនួនពីរនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងគណបក្សប្រជាជនកម្ពុជា និង គណបក្សហ៊្វុនស៊ីនប៉ិច ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ និង ចុះថ្ងៃទី៣0 ខែមិថុនា ឆ្នាំ២00៤ និង បានគោរពគោលការណ៍គតិយុត្តិទាំងឡាយយ៉ាងត្រឹមត្រូវដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ បច្ចុប្បន្ននេះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ចែកជា ១៦ជំពូក មាន ១៥៨ មាត្រា និង ច្បាប់ធម្មនុញ្ញបន្ថែមមួយមាន 0៧ មាត្រា។

សម្តេច អ្នកអង្គម្ចាស់ លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក អ្នកនាងកញ្ញា ជាទីគោរព !

ការធ្វើរដ្ឋធម្មនុញ្ញ ការធ្វើច្បាប់ លិខិតបទដ្ឋានទាំងឡាយជាការលំបាកមួយហើយ ប៉ុន្តែការគោរពការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និង លិខិតបទដ្ឋានទាំងឡាយ វាពិតជាជួបការលំបាកខ្លាំងណាស់នៅលើផ្លូវ

មួយដ៏វែងឆ្ងាយ ។ ដូច្នេះទាមទារឱ្យមានការព្យាយាម ការអត់ធ្មត់ ទស្សនៈគ្រប់ជ្រុងជ្រោយ ទៅតាមកាលៈទេសៈ តាមបរិបទសង្គមជាតិ ។ យើងគួរពិចារណាទៅលើពាក្យស្លោកមួយថា "**អ្នកចេះច្បាប់ច្រើនបង្រៀនអ្នកចេះច្បាប់តិច អ្នកចេះច្បាប់តិចបង្រៀនអ្នកមិនចេះច្បាប់**" ។

ជាទីបញ្ចប់ទូលបង្គំ ខ្ញុំសូមអរព្រះគុណ អរគុណជាថ្មីម្តងទៀតចំពោះវត្តមានសម្តេច អ្នកអង្គម្ចាស់ លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា និង គោរពថ្វាយព្រះពរ ជូនពរសូមជួបប្រទះតែនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ និង អរគុណ ។**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

# សុន្ទរកថា
# ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
# ថ្លែងបើកក្នុងឱកាសពិធីអបអរសាទរខួបឆ្នាំទី ១៩ ទិវាប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ
# នៃព្រះរាជាណាចក្រកម្ពុជា (២៤/០៩/១៩៩៣-២៤/០៩/២០១២)

-សូមថ្វាយបង្គំសម្តេច អ្នកអង្គម្ចាស់ និង សូមគោរពលោកជំទាវ ឯកឧត្តម លោកស្រី អស់លោក អ្នកនាងកញ្ញា ទាំងអស់ជាទីគោរព

ក្រោយពីស្តាប់ដោយយកចិត្តទុកដាក់បទអន្តាគមន៍ និង បាឋកថារបស់សម្តេច ឯកឧត្តម លោកជំទាវ ទាំង...... រូប ក្នុងនាមគណៈអធិបតី ទូលបង្គំខ្ញុំសូមថ្លែងនូវការគោរពកោតសរសើរយ៉ាងជ្រាលជ្រៅដល់សម្តេច ឯកឧត្តម លោកជំទាវ ដែលបានលើកឡើងនូវខ្លឹមសារនៃជំពូកទាំងឡាយនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ជាការពិតណាស់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលមានអាយុ ១៩ ឆ្នាំហើយប្រៀបធៀបទៅនឹងវ័យរបស់មនុស្សគឺជានីតិជនពេញលក្ខណៈ។ របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និង សិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋត្រូវបានគោរព និង អនុវត្តប្រកបដោយជោគជ័យ និង ផ្លែផ្កា។ យើងនៅចងចាំថា ស្ថានភាពកម្ពុជាពេលនោះលំបាកស្មុគស្មាញបំផុត ប៉ុន្តែដោយមានការស្រុះស្រួលគ្នារវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់គណបក្សធំទាំងបីដែលមានអាសនៈនៅក្នុងសភាធម្មនុញ្ញ យើងបានដោះស្រាយតាមគំនិតប្រាជ្ញាខ្មែរសុទ្ធសាធ ដែលបញ្ហាខ្លះគ្មានចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ក៏ដូចជាគ្មានចែងក្នុងកម្មវិធីបេសកកម្មរបស់អ៊ុនតាក់ទេ ។ ឧទាហរណ៍ជាក់ស្តែងមួយចំនួនមានដូចខាងនេះ÷

១-រដ្ឋាភិបាលនៃរដ្ឋកម្ពុជា និង គណបក្សប្រជាជនកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍មួយ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩១ ថ្កោលទោសរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និងទទួលស្គាល់សម្តេចព្រះ **នរោត្តម សីហនុ** ជាព្រះប្រមុខរដ្ឋនៃកម្ពុជា។

២-កិច្ចព្រមព្រៀងរវាងគណបក្សប្រជាជនកម្ពុជា និង ហ៊្វុនស៊ិនប៉ិច ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩១ មាន ៦ប្រការ សំដៅបង្កើតការជឿទុកចិត្តគ្នា ដើម្បីថែរក្សាស្ថិរភាពនយោបាយ និង បង្កលក្ខណៈសម្បត្តិថ្វាយចំពោះ

សម្ដេចព្រះ **នរោត្តម សីហនុ** បំពេញព្រះរាជបេសកកម្មជូនជាតិបានល្អ។

៣-ការបង្កើតរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជាមានសហនាយករដ្ឋមន្ត្រី និង មានកម្មវិធីនយោបាយរយៈពេលបីខែ។

៤-សភាធម្មនុញ្ញអនុម័តសេចក្ដីសម្រេចចិត្តថ្វាយដល់សម្ដេចព្រះ **នរោត្តម សីហនុ** នូវអំណាចជាព្រះប្រមុខរដ្ឋនៃកម្ពុជា ដោយចាត់ទុករដ្ឋប្រហារថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ ជាអំពើខុសច្បាប់ ព្រមទាំងអនុម័តយកទង់ជាតិ និង ភ្លេងជាតិពីសង្គមវិញ។

៥-ការសម្រេចចិត្តដ៏មានសារៈសំខាន់បំផុត គឺជ្រើសរើសយករបបរាជានិយមអាស្រ័យ រដ្ឋធម្មនុញ្ញដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាច ដូចជារបបរាជានិយមបណ្ដាប្រទេសមាន អង់គ្លេស ជប៉ុន ថៃ ។ល។

៦-ការរៀបចំសមាសភាពរាជរដ្ឋាភិបាលអាណត្តិទី១ នៃរដ្ឋសភា ដោយមាននាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីទីស្ដីការគណៈរដ្ឋមន្ត្រី ។

៧-ការអនុវត្តគោលនយោបាយឈ្នះ ឈ្នះ ដើម្បីបង្រួបបង្រួមផ្សះផ្សាជាតិ ឯកភាពជាតិ ឯកភាពទឹកដី សន្តិភាពទូទាំងព្រះរាជាណាចក្រកម្ពុជា និង ការអភិវឌ្ឍន៍ប្រកបដោយជោគជ័យចាប់ពីចុងឆ្នាំ១៩៩៨ មកដល់សព្វថ្ងៃ ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ពិតជាច្បាប់កំពូលមួយដ៏មានតម្លៃ និង មានសារៈសំខាន់បំផុតនេះ តម្រូវឱ្យពលរដ្ឋខ្មែរបន្តស្វែងយល់ឱ្យអស់នូវខ្លឹមសារ និង ពង្រឹងបាននូវសាមគ្គីភាព ឯកភាពជាតិរឹងមាំ ដើម្បីការពារឯករាជ្យជាតិ អធិបតេយ្យ បូរណភាពទឹកដី សន្តិភាព និង ការអភិវឌ្ឍន៍រុងរឿងតរៀងទៅ ស្របទៅនឹងនិន្នាការតំបន់ភាវូបនីយកម្ម និង សកលភាវូបនីយកម្ម។

ទូលបង្គំ ខ្ញុំសូមអរព្រះគុណ និង សូមអរគុណជាថ្មីម្ដងទៀតចំពោះសម្ដេច អ្នកអង្គម្ចាស់ លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា ដែលបានលះបង់ពេលវេលាដ៏មានតម្លៃមកចូលរួម ដែលញ៉ាំងឱ្យពិធីនេះមានភាពអធឹកអធម ។ ព្រមជាមួយនេះ សាជាថ្មីម្ដងទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់ លោក **ដេនីស ស្រ្ទេយ** (Denis Schrey) តំណាងមូលនិធិខុនរ៉ាដអាដិនណៅអ៊ែ (Konrad Adenauer Stiftung) ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានសហការ និង ឧបត្ថម្ភញ៉ាំងឱ្យពិធីថ្ងៃនេះបានប្រព្រឹត្តទៅដោយជោគជ័យ។

សូមប្រកាសបិទពិធីអបអរសាទរ ខួបឆ្នាំទី១៩ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង សូមថ្វាយព្រះពរ សូមជូនពរ គណៈអធិបតី និង សមាជិក សមាជិកា នៃអង្គពិធីទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរព្រះគុណ និង អរគុណ។